# 53 외국인 등록을 하러 가요
## ទៅចុះបញ្ជីឈ្មោះជនបរទេស

**학습 안내**
ការណែនាំអំពីមេរៀន

- □ **វត្ថុបំណងមេរៀន** ទទួលយកការត្រួតពិនិត្យចូលប្រទេស, ការសុំចុះបញ្ជីឈ្មោះជនបរទេស
- □ **សកម្មភាព** ការយល់ដឹងអំពីការបណ្ដុះបណ្ដាលការងារ
- □ **ពាក្យថ្មី** នីតិវិធីចូលប្រទេស, ការចុះបញ្ជីឈ្មោះជនបរទេស
- □ **ព័ត៌មាន · វប្បធម៌** ការចុះបញ្ជីឈ្មោះជនបរទេស

## 대화 1 ការសន្ទនា 1

Track 163



ខាងក្រោមនេះគឺជាការសន្ទនារវាងអ៊ីបាននិងបុគ្គលិកព្រលានយន្តហោះ។ សូមស្ដាប់ការសន្ទនាឲ្យបាន ២ដងជាមុនសិន រួចហើយចូរថាតាម។

**직원** 안녕하세요. 여권하고 입국 신고서 주세요.
ជម្រាបសួរ។ សូមឲ្យលិខិតឆ្លងដែននិងសលាកប័ត្រចូលមកខ្ញុំ។

**이반** 네, 여기 있습니다. បាទ, នៅទីនេះ។

**직원** 한국에는 무슨 일로 오셨어요?
តើអ្នកមានគោលបំណងអ្វី ទើបបានជាមកប្រទេសកូរ៉េ?

**이반** 고용허가제로 일하러 왔어요.
ខ្ញុំមកធ្វើការក្រោមប្រព័ន្ធអនុញ្ញាតមុខរបរ។

**직원** 어디에서 일하실 예정이시죠?
តើនឹងមានគម្រោងធ្វើការនៅឯណា?

**이반** 가구 공장에서 일하게 됐습니다.
ខ្ញុំត្រូវទៅធ្វើការនៅឯរោងចក្រគ្រឿងសង្ហារិម។

**직원** 3년 계약이시네요. 비자랑 서류 확인되셨고요.
វាជាកិច្ចសន្យា៣ឆ្នាំ។ ទិដ្ឋាការនិងឯកសារត្រូវបានពិនិត្យរួចរាល់អស់ហើយ។

여기에 손가락 대 주시고요, 이쪽에 있는 카메라 보세요.
សូមដាក់ម្រាមដៃនៅទីនេះ ហើយមើលមកម៉ាស៊ីនថតរូបនៅខាងនេះ។

> **랑/이랑** និង
> វាមានអត្ថន័យដូចគ្នាទៅនឹង‘와/과’ដែរ ជាពាក្យសម្រាប់ភ្ជាប់រវាងនាមនិងនាម។ ‘와/과’ត្រូវបានប្រើប្រាស់នៅក្នុងភាសាសរសេរ ចំណែកឯ‘랑/이랑’វិញ ត្រូវបានប្រើប្រាស់នៅក្នុងភាសានិយាយ។ វាអាចផ្លាស់ប្ដូរការប្រើប្រាស់ជាមួយនឹង‘하고’បាន។
> · 이 집으로 이사올 때 회사 동료들이랑 고향 친구들이 많이 도와줬어요.
> នៅពេលដែលរើមកផ្ទះនេះ មិត្តរួមការងារក្រុមហ៊ុននិងមិត្តភក្តិស្រុកកំណើតបានជួយខ្ញុំជាច្រើន។



តើអ្នកបានស្ដាប់និងថាតាមការសន្ទនារួចហើយមែនដែររឺទេ? អញ្ចឹងសូមសាកល្បងឆ្លើយនឹងសំណួរខាងក្រោម។

1. 이반 씨는 어디에서 일할 거예요? តើអ៊ីបាននឹងធ្វើការនៅឯណា?
2. 이반 씨는 얼마 동안 일할 예정이에요? តើអ៊ីបានមានគម្រោងនឹងធ្វើការរយៈពេលប៉ុន្មានឆ្នាំ?

**정답** 1. 가구 공장에서 일할 거예요. 2. 3년 동안 일할 예정이에요.

## 어휘 1 ពាក្យថ្មី 1 | 입국 절차 នីតិវិធីចូលប្រទេស



ខាងក្រោមនេះគឺជាពាក្យថ្មីជាច្រើនដែលទាក់ទងទៅនឹងនីតិវិធីចូលប្រទេស។ តើមានពាក្យអ្វីខ្លះ? តោះ! ស្វែងយល់ទាំងអស់គ្នា។





비자/사증
ទិដ្ឋាការ



여권
លិខិតឆ្លងដែន



유효 기간
រយៈពេលដែលមានសុពលភាព



발급을 신청하다
ដាក់ពាក្យស្នើសុំធ្វើ(ឯកសារ)



발급 받다
ទទួលការផ្តល់ឲ្យ



통역
បកប្រែ(ភាសា)



입국하다
ការចូលប្រទេស



입국 심사를 받다
ទទួលយកការត្រួតពិនិត្យចូលប្រទេស



입국이 금지되다
ត្រូវបានហាមឃាត់មិនឲ្យចូលប្រទេស



취업교육을 받다
ទទួលយកការបណ្តុះបណ្តាលការងារ



작업장에 배치되다
ត្រូវបានចាត់តាំងទៅតាមទីកន្លែងការងារ





입국신고서
សលាកប័ត្រចូល



សូមកុំមើលពាក្យដែលនៅខាងមុខ ហើយសាកល្បងឆ្លើយសំណួរខាងក្រោម។

1. 그림에 맞는 표현을 〈보기〉에서 골라 넣으세요.
   សូមជ្រើសរើសកន្សោមពាក្យពី<ឧទាហរណ៍>យកមកបំពេញឲ្យបានត្រឹមត្រូវទៅនឹងរូបភាព។

 →  →  →  → 

1) ______ 2) ______ 3) ______ 4) ______ 5) ______

**보기**
입국하다　　작업장에 배치되다　　취업 교육을 받다
사증을 발급받다　　근로 계약이 체결되다

2. 빈칸에 맞는 표현을 골라 대화를 완성하세요.
   សូមជ្រើសរើសយកកន្សោមពាក្យដែលត្រឹមត្រូវទៅនឹងចន្លោះមកបញ្ចប់ការសន្ទនា។

1)
가: 한국에 가면 바로 회사에서 일해요?
ប្រសិនបើទៅដល់ប្រទេសកូរ៉េ ចូលធ្វើការនៅក្រុមហ៊ុនបានភ្លាមរឺ?
나: 아니요, 2박 3일 동안 ______________을/를 받아요.
អត់ទេ, ទទួលយកការបណ្តុះបណ្តាលការងាររយៈពេល២យប់៣ថ្ងៃសិន។

① 입국 심사　　② 취업 교육

2)
가: ______________ 할 때 보통 뭘 물어봐요? ជាធម្មតាតើគេសួរអំពីអ្វីខ្លះពេលត្រួតពិនិត្យចូលប្រទេស?
나: 한국에 온 목적이랑 체류 기간 같은 것을 물어봐요.
សួរសំណួរដូចជាគោលបំណងមកប្រទេសកូរ៉េនិងរយៈពេលស្នាក់នៅជាដើម។

① 입국 심사　　② 작업장 배치

3)
가: 입국 심사에서 실수를 할까 봐 걱정이에요.
ខ្ញុំព្រួយបារម្ភណ៍ក្រែងមានកំហុសឆ្គងក្នុងការត្រួតពិនិត្យចូលប្រទេស។
나: 혹시 한국어를 이해할 수 없으면 ______________을 신청할 수 있어요.
ប្រសិនបើមិនយល់ភាសាកូរ៉េទេ អ្នកអាចដាក់ពាក្យស្នើសុំការបកប្រែបាន។

① 통역　　② 교육

4)
가: 여권 유효 기간이 얼마 안 남았네요.
សុពលភាពនៃលិខិតឆ្លងដែនរបស់អ្នកមិនសល់ប៉ុន្មានទៀតនោះទេ។
나: 네, 그래서 다음 주에 다시 ______________을 받으러 가려고 해요.
បាទ/ចាំ, ដូចនេះ ខ្ញុំមានគម្រោងនឹងទៅទទួលការផ្តល់ឲ្យសាជាថ្មីនៅអាទិត្យក្រោយ។

① 신청　　② 발급

**정답** 1. 1) 근로 계약이 체결되다　2) 사증을 발급받다　3) 입국하다
4) 취업 교육을 받다　5) 작업장에 배치되다
2. 1) ②　2) ①　3) ①　4) ②

## 대화 2 ការសន្ទនា 2

Track 164



ខាងក្រោមនេះគឺជាការនិយាយអំពីប្រព័ន្ធចុះបញ្ជីឈ្មោះជនបរទេស។ ដំបូងសូមស្ដាប់ការនិយាយឲ្យបាន២ដងជាមុនសិន។

강연자 여러분들이 한국에서 신분을 보장받기 위해서는 외국인 등록을 하셔야 합니다. 외국인 등록을 하는 방법은 간단합니다.

외국인 등록은 한국에 들어오신 후 90일 이내에 일하시는 곳 근처의 출입국 관리사무소에 가셔서 하시면 됩니다. 등록하실 때는 여권과 사진 2장, 그리고 일하고 계신 곳의 사업자 등록증을 가지고 가셔야 합니다. 외국인 등록증을 만드는 데는 3만원의 수수료가 필요합니다.

그리고 여권의 유효기간이 만료되어 갱신을 하신 경우에도 다시 외국인 등록을 하셔야 된다는 사실도 꼭 알아 두시기 바랍니다.

신분을 보장받다
ទទួលបានការគាំពារអត្តសញ្ញាណ

갱신을 하다
បន្ត

만료되다
ត្រូវបានផុតកំណត់

ដើម្បីទទួលបានការគាំពារអត្តសញ្ញាណនៅក្នុងប្រទេសកូរ៉េ អ្នកទាំងអស់គ្នាត្រូវតែស្នើសុំចុះបញ្ជីឈ្មោះជនបរទេស។ វិធីនៃការស្នើសុំចុះបញ្ជីឈ្មោះជនបរទេសមានភាពងាយស្រួល។ ក្រោយពេលដែលចូលមកដល់ប្រទេសកូរ៉េ ក្នុងកំឡុងពេល៩០ថ្ងៃអ្នកអាចទៅចុះបញ្ជីឈ្មោះជនបរទេសនៅការិយាល័យអន្តោប្រវេសន៍ដែលស្ថិតនៅក្បែរកន្លែងធ្វើការងាររបស់អ្នក។ នៅពេលដែលអ្នកទៅស្នើសុំចុះបញ្ជីឈ្មោះ ត្រូវតែនាំយកទៅជាមួយនូវលិខិតឆ្លងដែន រូបថតចំនួន២សន្លឹកព្រមទាំងប័ណ្ណចុះបញ្ជីអាជីវកម្មពីកន្លែងដែលអ្នកកំពុងតែធ្វើការទៅជាមួយផង។ ការធ្វើអត្តសញ្ញាណប័ណ្ណជនបរទេសត្រូវការថ្លៃសេវាចំនួន៣ម៉ឺនវ៉ុន។ នៅក្នុងករណីដែលសុពលភាពនៃលិខិតឆ្លងដែនត្រូវបានផុតកំណត់ ហើយអ្នកបានបន្តសុពលភាពនៃលិខិតឆ្លងដែនរបស់អ្នក ពេលនោះសូមចងចាំទុកថា អ្នកក៏ត្រូវតែទៅស្នើសុំចុះបញ្ជីឈ្មោះជនបរទេសសាជាថ្មីឡើងវិញដែរ។



ម្ដងនេះសូមធ្វើជាតួអង្គវាគ្មិននិងថាតាមអត្ថបទខាងលើ រួចហើយសូមសាកល្បងឆ្លើយនឹងសំណួរខាងក្រោម។

1. 외국인 등록은 언제 해야 해요? តើការស្នើសុំចុះបញ្ជីឈ្មោះជនបរទេសត្រូវតែធ្វើនៅពេលណា?
2. 외국인 등록을 하려면 뭐가 필요해요? ប្រសិនបើចង់ស្នើសុំចុះបញ្ជីឈ្មោះជនបរទេស តើត្រូវការអ្វីខ្លះ?

정답
1. 한국에 들어온 후 90일 이내에 해야 해요.
2. 여권, 사진 2장, 일하는 곳의 사업자 등록증이 필요해요.

## 어휘 2 ពាក្យថ្មី 2 | 외국인 등록 ការចុះបញ្ជីឈ្មោះជនបរទេស



យើងនឹងរៀនពាក្យថ្មីៗដែលនិយាយទាក់ទងទៅនឹងការចុះបញ្ជីឈ្មោះជនបរទេស។



출입국 관리소
ការិយាល័យអន្តោប្រវេសន៍




외국인 등록을 하다
ស្នើសុំចុះបញ្ជីឈ្មោះជនបរទេស



사업자 등록증 사본
ច្បាប់ថតចម្លងនៃប័ណ្ណចុះបញ្ជីអាជីវកម្ម



수수료
ថ្លៃសេវា/កម្រៃជើងសា



외국인 등록증
អត្តសញ្ញាណប័ណ្ណជនបរទេស



번호표를 뽑다
ចាប់លេខ



지문을 등록하다
ផ្តិត/ស្កេនស្នាមម្រាមដៃ




외국인 등록 신청서
ពាក្យស្នើសុំចុះបញ្ជីឈ្មោះជនបរទេស



សូមកុំមើលពាក្យនៅខាងលើ ហើយសាកល្បងឆ្លើយសំណួរខាងក្រោម។

1. 그림에 맞는 표현을 〈보기〉에서 골라 넣으세요.
សូមជ្រើសរើសយកកន្សោមពាក្យពី<ឧទាហរណ៍>មកបំពេញឲ្យបានត្រឹមត្រូវទៅនឹងរូបភាព។

 →  →  → 

1) ____ 2) ____ 3) ____ 4) ____

보기

접수 번호를 뽑다 지문을 등록하다
신청서를 제출하다 외국인 등록증을 받다

2. 그림을 보고 알맞은 말을 연결하세요. សូមមើលរូបភាព បន្ទាប់មកផ្គូរភ្ជាប់ទៅនឹងពាក្យដែលត្រឹមត្រូវ។

①  • • ㉠ 수수료

②  • • ㉡ 번호표

③  • • ㉢ 신청서

④  • • ㉣ 외국인 등록증

⑤  • • ㉤ 사업자 등록증 사본

정답 1. 1) 접수 번호를 뽑다 2) 신청서를 제출하다
3) 지문을 등록하다 4) 외국인 등록증을 받다
2. ① ㉣ ② ㉤ ③ ㉠ ④ ㉢ ⑤ ㉡

## 활동 សកម្មភាព

**취업 교육에 대한 글입니다. 잘 읽고 질문에 답하세요.**
ខាងក្រោមនេះគឺជាអត្ថបទស្តីពីការបណ្តុះបណ្តាលការងារ។ សូមអានដោយយកចិត្តទុកដាក់ បន្ទាប់មកចូរឆ្លើយនឹងសំណួរ។

표준일보

?

20일 노사 발전 재단에 따르면 고용허가제로 입국해 취업 교육을 받은 외국인 근로자는 최근 5년 동안 크게 증가했다고 한다. 현재 고용허가제로 한국에 오는 모든 외국인 근로자는 사업장에 배치되기 전 16시간의 취업 교육을 받는다.




취업 교육에서의 교육 내용

2박 3일간의 취업 교육에서 외국인 근로자는 입국 전에 배운 한국어를 다시 점검하고, 한국의 직장 문화와 생활 방식, 근로 기준법을 비롯한 기본적인 법률과 제도, 산업 안전 등을 배운다.

박인상 대표 이사장은 "취업 교육은 외국인 근로자의 한국 적응을 돕고 중소기업의 인력난을 해소하며, 고용 허가제의 정착에 기여하여 왔다"고 밝히면서 취업 교육의 중요성을 강조했다.

យោងតាមមូលនិធិអភិវឌ្ឍន៍ពលកម្មនៅថ្ងៃទី២០បានលើកឡើងថា ចំនួនពលករបរទេសដែលបានចូលមកក្នុងប្រទេសក្រោមប្រព័ន្ធអនុញ្ញាតមុខរបរ ហើយព្រមទាំងទទួលបាននូវការបណ្តុះបណ្តាលការងារបានកើនឡើងជាខ្លាំងក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ។ បច្ចុប្បន្ននេះ ពលករបរទេសទាំងអស់ដែលមកប្រទេសកូរ៉េក្រោមប្រព័ន្ធអនុញ្ញាតមុខរបរ មុននឹងត្រូវបានចាត់តាំងទៅតាមទីកន្លែងការងារនានា ត្រូវទទួលការបណ្តុះបណ្តាលការងារចំនួន១៦ម៉ោងជាមុនសិន ។

ក្នុងរយៈពេល២យប់៣ថ្ងៃនៃការបណ្តុះបណ្តាលការងារ គឺពិនិត្យឡើងវិញនូវភាសាកូរ៉េដែលពលករបានរៀនមុនពេលចូលប្រទេស, ហើយរៀនអំពីវប្បធម៌កន្លែងធ្វើការនិងរបៀបរស់នៅក្នុងប្រទេសកូរ៉េ, រួមផ្សំទាំងការរៀនអំពីច្បាប់និងប្រព័ន្ធមូលដ្ឋាននៃច្បាប់បទដ្ឋានការងារ, សុវត្ថិភាពឧស្សាហកម្ម។ល។

លោកបាក់អ៊ីនសាំង ប្រធានក្រុមប្រឹក្សាភិបាលបានបង្ហាញនិងសង្កត់ធ្ងន់អំពីសារៈសំខាន់នៃការបណ្តុះបណ្តាលការងារថា៖ "ការបណ្តុះបណ្តាលការងារ ក្រោមការចូលរួមចំណែកពីប្រព័ន្ធអនុញ្ញាតមុខរបរបានជួយដល់ពលករបរទេសក្នុងការសម្របខ្លួនរស់នៅក្នុងប្រទេសកូរ៉េ ហើយព្រមទាំងដោះស្រាយបញ្ហាកង្វះខាតពលកម្មដល់អាជីវកម្មធន់តូចនិងមធ្យមបានថែមទៀតផង"។

1. 위 글의 제목으로 알맞은 것을 고르세요. សូមជ្រើសរើសចំណងជើងដែលត្រឹមត្រូវសម្រាប់អត្ថបទខាងលើនេះ។

① 취업 교육 … 근로자의 한국 적응 도와

② 외국인 근로자 10년 사이 큰 폭으로 늘어

③ 16시간의 취업 교육 … 프로그램 다양화되어야

④ 고용 허가제의 정착 … 법률과 제도 교육이 우선

정답 1. ①

## 정보 ព័ត៌មាន

# 외국인 등록

ការចុះបញ្ជីឈ្មោះជនបរទេស

### 외국인 등록이란? ដូចម្ដេចដែលហៅថាការចុះបញ្ជីឈ្មោះជនបរទេស?

대한민국에 90일을 초과하여 체류하는 외국인에 대하여 등록하도록 함으로써 장기 체류하는 외국인의 체류 현황 및 신분 관계를 정확히 파악하고, 이를 행정시책에 반영하여 국제법상 외국인에게 부여한 권리를 보호하는 것을 말합니다.

គឺជាការចុះបញ្ជីឈ្មោះចំពោះជនបរទេសទាំងឡាយណាដែលមកស្នាក់នៅក្នុងសាធារណៈរដ្ឋកូរ៉េលើសពីរយៈពេល៩០ថ្ងៃ។ ការចុះបញ្ជីឈ្មោះបែបនេះគឺដើម្បីឲ្យដឹងច្បាស់លាស់អំពីស្ថានភាពស្នាក់នៅ និងអត្តសញ្ញាណរបស់ជនបរទេសដែលមកស្នាក់នៅក្នុងរយៈពេលវែងផងដែរ។ វាឆ្លុះបញ្ចាំងនូវគោលនយោបាយរដ្ឋបាល ដើម្បីការពារសិទ្ធិជនបរទេសដែលបានផ្ដល់ឲ្យដោយច្បាប់អន្តរជាតិ។

### 대상 ជនដែលត្រូវជាប់កាតព្វកិច្ច

외국인 등록은 ① 대한민국에 입국한 날부터 90일을 초과하여 체류하려는 외국인 ② 대한민국 국적을 상실하고 외국 국적을 취득하였거나 우리나라에서 출생한 외국인 ③ 체류 자격을 부여받아 그날부터 90일을 초과하여 체류하려는 외국인 등 1, 2, 3에 해당하는 사람 모두 반드시 실시해야 합니다.

ចំពោះជនបរទេសទាំងឡាយណាដែលមានលក្ខខណ្ឌដូចដែលបានរៀបរាប់តទៅនេះ ត្រូវតែដាក់ពាក្យស្នើសុំចុះបញ្ជីឈ្មោះជនបរទេសកុំបីខាន។ ១.ជនបរទេសដែលមានបំណងចង់ស្នាក់នៅក្នុងសាធារណៈរដ្ឋកូរ៉េលើសពី៩០ថ្ងៃគិតចាប់ពីថ្ងៃចូលប្រទេស។ ២.ជាជនជាតិកូរ៉េ ប៉ុន្តែបាត់បង់សញ្ជាតិកូរ៉េរួចហើយមានសញ្ជាតិបរទេស រឺក៏ជនបរទេសដែលកើតនៅក្នុងសាធារណៈរដ្ឋកូរ៉េ។ ៣.ជនបរទេសដែលមានលក្ខខណ្ឌគ្រប់គ្រាន់សម្រាប់ការស្នាក់នៅនិងមានបំណងស្នាក់នៅលើសពី៩០ថ្ងៃ គិតចាប់ពីថ្ងៃដែលទទួលបាន។

### 시기 ពេលវេលាក្នុងការដាក់ពាក្យស្នើសុំ

· 대한민국에 90일을 초과하여 체류하고자 하는 외국인 → 입국 일부터 90일 이내

ជនបរទេសទាំងឡាយណាដែលមានបំណងចង់ស្នាក់នៅក្នុងសាធារណៈរដ្ឋកូរ៉េលើសពី៩០ថ្ងៃ → ក្នុងរយៈពេល៩០ថ្ងៃគិតចាប់ពីថ្ងៃចូលប្រទេស

· 체류자격 부여 또는 변경허가를 받은 외국인 → 그 허가를 받는 때(즉시)

ជនបរទេសទាំងឡាយណាដែលមានលក្ខខណ្ឌគ្រប់គ្រាន់សម្រាប់ស្នាក់នៅ រឺក៏ទទួលបានការអនុញ្ញាតឲ្យផ្លាស់ប្ដូរ(ទិដ្ឋាការ) → ពេលដែលទទួលបានការអនុញ្ញាត(ភ្លាមៗ)

### 장소 ទីកន្លែង

관할 출입국 관리 사무소 또는 출장소에서 신청접수를 합니다.

ដាក់ពាក្យស្នើសុំទៅការិយាល័យទទួលបន្ទុកអន្តោប្រវេសន៍រឺក៏ការិយាល័យសាខា។

### 서류 ឯកសារ

외국인 등록 신청서, 여권, 증명사진 2매(3.5cm x 4.5cm), 비전문 취업(E-9)의 경우 외국인 등록을 할 때는 사업자 등록증 사본, 수수료가 필요합니다.

ត្រូវការដូចជា៖ ពាក្យស្នើសុំចុះបញ្ជីឈ្មោះជនបរទេស, លិខិតឆ្លងដែន, រូបថតបញ្ជាក់អត្តសញ្ញាណចំនួន២សន្លឹក(៣.៥cm x ៤.៥cm), ក្នុងករណីអ្នកកាន់ទិដ្ឋាការការងារមិនមានវិជ្ជាជីវៈ(E-9) ពេលដែលសុំចុះបញ្ជីឈ្មោះជនបរទេស ត្រូវភ្ជាប់បន្ថែមមកជាមួយនូវច្បាប់ចម្លងនៃប័ណ្ណចុះបញ្ជីអាជីវកម្ម, ព្រមទាំងថ្លៃសេវាផងដែរ។

# EPS-TOPIK 듣기 វិញ្ញាសាស្ដាប់ EPS-TOPIK



ចាប់ពីសំណួរទី១ដល់ទី៣សូមស្ដាប់ការសន្ទនា បន្ទាប់មកជ្រើសរើសចម្លើយដែលត្រឹមត្រូវ។
សូមស្ដាប់ដោយយកចិត្តទុកដាក់ បន្ទាប់មកចូរជ្រើសរើសយកចម្លើយដែលត្រឹមត្រូវ។

[1~2] 이야기를 듣고 질문에 알맞은 대답을 고르십시오.
សូមស្ដាប់ការសន្ទនា បន្ទាប់មកចូរជ្រើសរើសយកចម្លើយដែលត្រឹមត្រូវទៅនឹងសំណួរ។

Track 165

1. 여자는 지금 무엇을 하고 있습니까? តើស្ត្រីម្នាក់នេះកំពុងតែធ្វើអ្វីនៅពេលនេះ?

① 사증을 발급 받고 있습니다. ② 서류를 제출하고 있습니다.
③ 입국 심사를 받고 있습니다. ④ 취업 교육을 받고 있습니다.

2. 두 사람은 무엇에 대해 이야기를 하고 있습니까? តើមនុស្សទាំង២នាក់នេះកំពុងតែនិយាយគ្នាអំពីអ្វី?

① 근로 계약 ② 입국 심사
③ 취업 교육 ④ 증명서 발급

3. 질문을 듣고 알맞은 대답을 고르십시오.
សូមស្ដាប់សំណួរ បន្ទាប់មកជ្រើសរើសយកចម្លើយដែលត្រឹមត្រូវ។

① 네, 여권이 필요해요. ② 네, 입국이 어려워요.
③ 네, 기간이 만료됐어요. ④ 네, 기간이 좀 남았어요.



សំណួរទី៤និងទី៥ តាមរយៈការស្ដាប់ការនិយាយតែមួយគត់ សូមឆ្លើយនឹងសំណួរទាំង២ខាងក្រោម។
មុននឹងស្ដាប់ការសន្ទនា សូមពិនិត្យមើលខ្លឹមសារនៃសំណួរនិងចម្លើយជាមុនសិន។

[4~5] 하나의 이야기를 듣고 두 개의 질문에 대답하십시오.
សូមស្ដាប់ការនិយាយតែមួយគត់ ចូរឆ្លើយនឹងសំណួរទាំង២។

4. 남자는 무엇을 하려고 합니까? តើបុរសម្នាក់នេះមានគម្រោងនឹងធ្វើអ្វី?

① 신청서를 제출하려고 합니다. ② 증명사진을 찍으려고 합니다.
③ 외국인 등록을 하려고 합니다. ④ 증명서를 발급 받으려고 합니다.

5. 필요한 서류가 아닌 것은 무엇입니까? តើអ្វីទៅដែលមិនមែនជាឯកសារចាំបាច់?

① 여권 ② 사증
③ 신청서 ④ 사업자 등록증 사본



## 듣기 대본 អត្ថបទនៅក្នុងវិញ្ញាសាស្ដាប់

1. 남: 한국에는 왜 오셨지요? ហេតុអ្វីបានជាអ្នកមកប្រទេសកូរ៉េ?
   여: 고용허가제로 일을 하러 왔습니다. ខ្ញុំបានមកធ្វើការក្រោមប្រព័ន្ធអនុញ្ញាតមុខរបរ។
   남: 네, 됐습니다. 이쪽에서 지문 등록해 주세요. បាទ, រួចរាល់អស់ហើយ។ សូមស្កេនស្នាមម្រាមដៃនៅខាងនេះ។
2. 남: 한국에 가면 바로 일을 해요? ប្រសិនបើទៅដល់ប្រទេសកូរ៉េ ចូលធ្វើការបានភ្លាមរឺ?
   여: 아니요, 일하기 전에 한국어도 공부하고, 업무도 배워요.
   អត់ទេ, មុននឹងចូលធ្វើការ រៀនភាសាកូរ៉េផង ហើយក៏រៀនអំពីការងារផងដែរ។
3. 여: 여권 유효 기간이 남았어요? តើលិខិតឆ្លងដែនរបស់អ្នកនៅមានសុពលភាពដែររឺទេ?

4-5.

남: 외국인 등록증을 만들려고 하는데요. ខ្ញុំមានបំណងចង់ធ្វើអត្តសញ្ញាណប័ណ្ណជនបរទេស។
여: 네, 신청서하고 여권, 증명사진, 사업자 등록증 사본 주세요.
ចាំ, សូមឲ្យពាក្យស្នើសុំនិងលិខិតឆ្លងដែន, រូបថតបញ្ជាក់អត្តសញ្ញាណ, ព្រមទាំងច្បាប់ថតចម្លងនៃប័ណ្ណចុះបញ្ជីអាជីវកម្មមកខ្ញុំ។

정답 1. ③ 2. ③ 3. ④ 4. ③ 5. ②

## 확장 연습 លំហាត់អនុវត្តបន្ថែម

L-53

1. 대화를 듣고 질문에 알맞은 것을 고르십시오.
សូមស្ដាប់ការសន្ទនា បន្ទាប់មកចូរជ្រើសរើសយកចម្លើយដែលត្រឹមត្រូវទៅនឹងសំណួរ។

남자가 걱정하는 이유는 무엇입니까? តើហេតុផលអ្វីដែលធ្វើឲ្យបុរសម្នាក់នេះព្រួយបារម្ភ?

① 체류 기간을 잘 몰라서
② 통역 일이 어려울까 봐
③ 통역을 신청할 수 없어서
④ 입국 심사 때 실수할까 봐

## 확장 연습 듣기 대본 អត្ថបទស្ដាប់នៅក្នុងលំហាត់អនុវត្តបន្ថែម

1. 남: 한국말을 잘 못해서 입국 심사를 어떻게 받을지 걱정이에요.
   ខ្ញុំមិនសូវចេះភាសាកូរ៉េ ហេតុនេះហើយពេលទទួលការត្រួតពិនិត្យចូលប្រទេសមិនដឹងថាត្រូវធ្វើយ៉ាងដូចម្ដេចនោះទេ ពិតជាបារម្ភណ៍ណាស់។
   여: 한국어를 못하는 사람들은 통역을 신청할 수 있으니까 너무 걱정하지 마세요.
   អ្នកដែលមិនចេះភាសាកូរ៉េអាចស្នើសុំការបកប្រែបាន ហេតុនេះកុំបារម្ភណ៍ពេកអី។
   남: 그래요? 다행이네요. 실수할까 봐 걱정했거든요. 그런데 입국 심사에서는 보통 뭘 물어봐요?
   ពិតមែនរឺ? ពិតជាសំណាងណាស់។ ខ្ញុំបានព្រួយបារម្ភណ៍ខ្លាចក្រែងមានកំហុសឆ្គង។ ប៉ុន្តែជាធម្មតា តើគេសួរអំពីអ្វីខ្លះពេលត្រួតពិនិត្យចូលប្រទេស?
   여: 한국에 입국하는 목적이랑 체류 기간 같은 것을 묻더라고요.
   គេបានសួរសំណួរអំពីគោលបំណងចូលប្រទេសកូរ៉េនិងរយៈពេលស្នាក់នៅជាដើម។

정답 1. ④

# EPS-TOPIK 읽기 វិញ្ញាសាអាន EPS-TOPIK



សំណួរទី១និងទី២គឺជាការមើលរូបភាព បន្ទាប់មកជ្រើសរើសប្រយោគដែលត្រឹមត្រូវ។
សូមអានដោយយកចិត្តទុកដាក់ បន្ទាប់មកចូរជ្រើសរើសយកចម្លើយដែលត្រឹមត្រូវទៅនឹងរូបភាព។

[1~3] 다음 그림을 보고 맞는 문장을 고르십시오.
សូមមើលរូបភាពខាងក្រោម បន្ទាប់មកចូរជ្រើសរើសយកប្រយោគដែលត្រឹមត្រូវ។

1. 

① 여권입니다. ② 사증입니다.
③ 사진입니다. ④ 수수료입니다.

2. 

① 신청서입니다. ② 입국 신고서입니다.
③ 외국인 등록증입니다. ④ 사업자 등록증입니다.

3. 

① 통역이 필요해요. ② 심사가 필요해요.
③ 신청을 해야 해요. ④ 등록을 해야 해요.



សំណួរទី៤និងទី៥ គឺជាការជ្រើសរើសចម្លើយដែលត្រឹមត្រូវដើម្បីបំពេញចន្លោះ។
សូមអានដោយយកចិត្តទុកដាក់ បន្ទាប់មកចូរជ្រើសរើសយកចម្លើយដែលត្រឹមត្រូវ។

[4~5] 빈칸에 들어갈 가장 알맞은 것을 고르십시오.
សូមជ្រើសរើសយកចម្លើយដែលត្រឹមត្រូវបំផុតដើម្បីបំពេញចន្លោះ។

4. 공공기관에서는 먼저 온 순서대로 업무를 볼 수 있도록 ______________ 합니다.
នៅតាមស្ថាប័នសាធារណៈ ដើម្បីធ្វើកិច្ចការតាមលំដាប់លំដោយនៃការដែលបានមកដល់មុន អ្នកត្រូវតែធ្វើការចាប់លេខ។

① 지문을 등록해야 ② 번호표를 뽑아야
③ 신청서를 제출해야 ④ 등록증을 발급 받아야

5. 등록증을 만들 때 본인이 맞는지 확인하기 위해서 손에 있는 ______________을 등록합니다.
នៅពេលធ្វើអត្តសញ្ញាណប័ណ្ណ ដើម្បីត្រួតពិនិត្យឲ្យដឹងថាខ្លួនអ្នកផ្ទាល់រឺក៏មិនមែន គឺគេស្កេនស្នាមម្រាមដៃ។

① 도장 ② 사인 ③ 서명 ④ 지문

정답 1. ① 2. ② 3. ① 4. ② 5. ④



## 확장 연습 លំហាត់អនុវត្តបន្ថែម

[1~3] 빈칸에 들어갈 가장 알맞은 것을 고르십시오. សូមជ្រើសរើសចម្លើយដែលត្រឹមត្រូវបំផុតដើម្បីបំពេញចន្លោះ។

1.

제 동생이 한국에서 일하게 되었습니다. 지난주에 회사와 ________을/를 했고 다음 달쯤 한국으로 떠날 예정입니다.

ប្អូនរបស់ខ្ញុំត្រូវបានទៅធ្វើការនៅប្រទេសកូរ៉េហើយ។ អាទិត្យមុនបានចុះកិច្ចសន្យាជាមួយក្រុមហ៊ុន ហើយប្រហែលជាខែក្រោយគ្រោងនឹងចាកចេញទៅប្រទេសកូរ៉េ។

① 해고 ② 고용
③ 계약 ④ 보상

2.

외국인 등록증을 ________ 증명사진이 필요합니다. 그래서 회사 앞에 있는 사진관에 가서 사진을 찍었습니다.

ប្រសិនបើចង់ធ្វើអត្តសញ្ញាណប័ណ្ណជនបរទេស គឺត្រូវការរូបថតបញ្ជាក់អត្តសញ្ញាណ។ ដូចនេះ ខ្ញុំបានទៅថតរូបនៅឯកន្លែងថតរូបដែលនៅពីមុខក្រុមហ៊ុន។

① 만들어서 ② 만들던데
③ 만들려면 ④ 만들다가

3.

비자에 문제가 생겨서 출입국관리사무소에 전화를 했습니다. 전화를 받은 직원이 친절하게 해결방법을 ________ 주었습니다.

ទិដ្ឋាការមានបញ្ហាកើតឡើង ហេតុនេះហើយខ្ញុំបានទូរស័ព្ទទៅការិយាល័យជនអន្តោប្រវេសន៍។ បុគ្គលិកដែលបានលើកទូរស័ព្ទបានផ្តល់ព័ត៌មាននៃវិធីដោះស្រាយយ៉ាងរួសរាយរ៉ាក់ទាក់។

① 문의해 ② 안내해
③ 신청해 ④ 신고해

정답 1. ③ 2. ③ 3. ②

## 발음 ការបញ្ចេញសម្លេង

P-29

### សូមស្តាប់ដោយយកចិត្តទុកដាក់រួចថាតាម

នៅពេល '-(으)ㄹ' ដែលជាទម្រង់ធ្វើឲ្យមានការប្រែប្រួលការបញ្ចេញសម្លេងនាំពីក្រោយវាដោយពពួកសម្លេងព្យញ្ជនៈបំពង់កដែលមានដូចជា៖ 'ㄱ, ㄷ, ㅂ, ㅅ, ㅈ' ពេលនោះនឹងប្រែប្រួលការបញ្ចេញសម្លេងទៅជាសម្លេងធ្ងន់ [ㄲ], [ㄸ], [ㅃ], [ㅆ], [ㅉ] វិញ។

(1) 먹을 것, 살 곳, 올 사람
(2) 죽을 병, 갈 곳
(3) 먹을 것이 많아요.
(4) 주말에 갈 곳이 없어요.